**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកក្កដា និងទិសដៅការងារខែសីហា ឆ្នាំ២០២៥

នៅក្នុងខែកក្កដា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយទទួលបានលទ្ធផលដូចខាងក្រោមៈ

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- **បានរៀបចំចាត់ចែង និងផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារនីតិកម្មៈ**

  ❖ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលមានរបៀបវារៈ ដូចខាងក្រោមៈ

  ១- ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ សុំដាក់សេចក្ដីស្នើច្បាប់ធម្មនុញ្ញស្ដីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។

  ២- ពិនិត្យ និងសម្រេចលើសំណើរបស់សមាជិកព្រឹទ្ធសភា ស្នើសុំកោះប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ និង

  ៣- កំណត់កាលបរិច្ឆេទ របៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។

  ❖ បើកសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីស្នើច្បាប់ធម្មនុញ្ញស្ដីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

- ❖ កិច្ចប្រជុំជាមួយតំណាងក្រុមតំណាងរាស្ត្រហត្ថលេខី និងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង
- ❖ ប្រជុំគណៈកម្មការពិសេស ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

## ២-មុខងារតាមដានការអនុវត្តច្បាប់

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការដោះស្រាយ និងចក្ខុវិស័យពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ស្ពឺ និងខេត្តកោះកុង។

## ៣-មុខងារតំណាង

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖**
  - ❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**
    - ▪ **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
      - បានអញ្ជើញដង្ហែ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះរាជពិធី "រុក្ខទិវា" នៅស្រុកចំការលើ ខេត្តកំពង់ចាម។
      - បាន និងកំពុងរួមចំណែកជាមួយរាជរដ្ឋាភិបាល និងវីរយុទ្ធជននៅគ្រប់លំដាប់ថ្នាក់នៃគ្រប់ទីតាំងបញ្ជាការដ្ឋានជួរមុខតាមបណ្តោយព្រំដែនកម្ពុជា ផ្តល់ប្រឹក្សាយោបល់យុទ្ធសាស្ត្រ និងការលើកទឹកចិត្តគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុការពារបូរណភាពទឹកដីដែនអធិបតេយ្យជាតិ និងអាយុជីវិតរបស់ពលរដ្ឋពីការឈ្លានពានរបស់កងទ័ពថៃ។
      - បានអញ្ជើញតាមដានសភាពការណ៍វិវាទព្រំដែនកម្ពុជា-ថៃ និងផ្តល់ប្រឹក្សាយោបល់យុទ្ធសាស្ត្រយោធា ដល់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** និងបណ្តាមេទ័ព ដើម្បីវាយខ្ទាំងឈ្លានពាន។
      - បានអញ្ជើញចុះពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ នៅស្រុកកំចាយមារ ខេត្តព្រៃវែង។
      - បានអញ្ជើញជួបសំណេះសំណាលជាមួយសិស្ស និស្សិត និងលោកគ្រូ អ្នកគ្រូនៃមជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាល ជា ស៊ីម កំចាយមារ សរុបជាង១ពាន់នាក់ នៅស្រុកកំចាយមារ ខេត្តព្រៃវែង។
      - បានអញ្ជើញចូលរួមពិធីសូត្រមន្តក្នុងឱកាសពិធីបុណ្យខួបគម្រប់១០ឆ្នាំ និងគម្រប់ខួប១៦ឆ្នាំ នៃការចូលមរណភាពរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** អតីតប្រធានព្រឹទ្ធសភា និង**លោកជំទាវ ញ៉ែម សឿន ជាស៊ីម** នៅស្រុកកំចាយមារ ខេត្តព្រៃវែង។

- បានអញ្ជើញចូលរួមពិធីសាសនាផ្សេងៗ រួមទាំងពិធីបង្សុកូល និងរាប់បាត្រ ក្នុងពិធីបុណ្យគម្រប់ខួប១០ឆ្នាំ និងគម្រប់ខួប១៦ឆ្នាំ នៃការចូលមរណភាពរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** អតីតប្រធានព្រឹទ្ធសភា និង**លោកជំទាវ ញ៉ែម សឿន ជាស៊ីម** នៅស្រុកកំចាយមារ ខេត្តព្រៃវែង និង
- បានអញ្ជើញជាអធិបតីក្នុងពិធីបុណ្យទក្ខិណានុប្បទានគម្រប់ខួប១០០ថ្ងៃ ដើម្បីឧទ្ទិសមហាកុសលជូនដួងវិញ្ញាណក្ខន្ធ **ឯកឧត្តមអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** នៅខណ្ឌទួលគោក រាជធានីភ្នំពេញ។

❖ **ឯកឧត្តម អ៊ុំ ឆ្វូរិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖**
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងជាមួយអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុស្តីពីការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ២០២៥-២០២៦ របស់ព្រឹទ្ធសភា នៅបន្ទប់ប្រជុំខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ វិមានព្រឹទ្ធសភា។
  - បានអញ្ជើញដឹកនាំប្រជុំជាមួយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដើម្បីពិនិត្យ និងពិភាក្សាលើរបៀបវារៈចំនួន៣ មានដូចខាងក្រោម៖
    - ១/ របាយការណ៍លទ្ធផលស្តីពី ការចុះជួបសំណេះសំណាលជាមួយអង្គបោះឆ្នោតកន្លងមក (បញ្ហាប្រឈម និងសំណូមពរ)។
    - ២/ សេចក្តីព្រាងកម្មវិធីលម្អិតសម្រាប់ការចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងខេត្តកំពង់ចាម នាពេលខាងមុខ និង
    - ៣/ បញ្ហាផ្សេងៗ។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញអមដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភាអញ្ជើញចុះពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ នៅស្រុកកំចាយមារ ខេត្តព្រៃវែង។
  - បានអញ្ជើញចូលរួមពិធីសំណេះសំណាលជាមួយសិស្ស និស្សិត និងលោកគ្រូ អ្នកគ្រូនៃមជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាល ជា ស៊ីម កំចាយមារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅស្រុកកំចាយមារ ខេត្តព្រៃវែង។
  - បានអញ្ជើញចូលរួមពិធីបុណ្យពុទ្ធាភិសេក និងឆ្លងសារមន្ទីរ ពិស្តារប្រាំពីរចប់ និងខួបគម្រប់១០ឆ្នាំ និងគម្រប់១៦ឆ្នាំ ជូន **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** អតីតប្រធានព្រឹទ្ធសភា និង**លោកជំទាវ ញ៉ែម សឿន ជាស៊ីម** នៅស្រុកកំចាយមារ ខេត្តព្រៃវែង។
  - បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបុណ្យឯករាជ្យជាតិ ខួបលើកទី២៤៩ នៃសហរដ្ឋអាមេរិក ដែលរៀបចំដោយស្ថានទូតសហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ភូគីត្រា និង
  - បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមឧត្តមសេនីយ៍ឯក ដួង សំនៀង** មេបញ្ជាការកងពលតូចអន្តរាគមន៍លេខ៧ កងពលធំ

អន្តរាគមន៍លេខ៣ កងទ័ពជើងគោក សព **លោកព្រិន្ទបាលទោ ផៃ វត្ថ** និងសព **លោកអនុសេនីយ៍ត្រី ភាព សោភ័ណ** នៅរាជធានីភ្នំពេញ ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម។

- **ឯកឧត្តមបណ្ឌិត ឆន់ ទង្សនា អនុប្រធានទី២ព្រឹទ្ធសភា៖**
  - **សកម្មភាពដឹកនាំកិច្ចប្រជុំ៖**
    - បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយទីប្រឹក្សា ថ្នាក់ដឹកនាំ និងសមាជិកខុទ្ទកាល័យ ដើម្បីពិនិត្យវឌ្ឍនភាពការងារ និងកំណត់ផែនការការងាររបស់ខុទ្ទកាល័យសម្រាប់ត្រីមាសខាងមុខ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
    - បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែជាមួយប្រធានគណៈកម្មការទាំង១០ព្រឹទ្ធសភា ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ប្រធានក្រុមសមាជិកា និងប្រធានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
    - បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ដើម្បីរៀបចំក្រុមដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តពិនិត្យជំងឺជូនប្រជាពលរដ្ឋ រៀបចំពិធីសំណេះសំណាល និងវេទិកាជាមួយអង្គបោះឆ្នោត នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង
    - បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយវិស័យឯកជន និងស្ថាប័នពាក់ព័ន្ធ និងកំណត់កិច្ចការត្រូវធ្វើ រួមមាន៖ ការកែច្នៃអាហារ ការផលិតពូជដំណាំ និងផ្កា ការផលិតជី ការបង្កើតប្រព័ន្ធគ្រប់គ្រងឌីជីថល និងការរួមគ្នាបង្កើតផ្សារសម្រាប់ផលិតផលខ្មែរ ដោយមានការចូលរួមពីសាកលវិទ្យាល័យរដ្ឋ ចំនួន២០ វិស័យឯកជន និងស្ថាប័នពាក់ព័ន្ធ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
  - **សកម្មភាពចុះមូលដ្ឋាន៖**
    - បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខ និងចែកអំណោយសម្រាលទុក្ខលំបាកប្រជាពលរដ្ឋភៀសសឹក ចំនួន៤០០គ្រួសារ នៅខេត្តបន្ទាយមានជ័យ។
    - បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខ និងចែកអំណោយសម្រាលទុក្ខលំបាកប្រជាពលរដ្ឋភៀសសឹក ប្រមាណ២០,០០០នាក់ នៅវត្តពោធិ៍៥០០០ដើម ខេត្តព្រះវិហារ និង
    - បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខ និងចែកអំណោយសម្រាលទុក្ខលំបាកប្រជាពលរដ្ឋភៀសសឹក ចំនួន២,០៥០គ្រួសារ នៅខេត្តឧត្តរមានជ័យ។
  - **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
    - បានអញ្ជើញថ្លែងសុន្ទរកថាបិទកិច្ចប្រជុំក្រុមអ្នកនយោបាយអន្តរសភាអាស៊ានលើកទី១៦ (The 16th AIPA Caucus) នៅវិមានរដ្ឋសភា។

- បានអញ្ជើញជាអធិបតី និងថ្លែងសុន្ទរកថាគន្លឹះ ក្នុងកម្មវិធីផ្សព្វផ្សាយសៀវភៅ "ទិនានុប្បវត្តិលេខ៨ និងវេទិកាពិភាក្សាលើការស្រាវជ្រាវអំពីមហាតំបន់ទន្លេមេគង្គ" របស់វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) នៅសណ្ឋាគារ រ៉ាហ្វលស៍ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ។
- បានអញ្ជើញអមដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញចុះពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ នៅស្រុកកំចាយមារ ខេត្តព្រៃវែង។
- បានអញ្ជើញចូលរួមពិធីសំណេះសំណាលជាមួយសិស្ស និស្សិត និងលោកគ្រូ អ្នកគ្រូ នៃមជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាល ជា ស៊ីម កំចាយមារ ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅស្រុកកំចាយមារ ខេត្តព្រៃវែង។
- បានអញ្ជើញចូលរួមពិធីបុណ្យពុទ្ធាភិសេក និងឆ្លងសារមន្ទីរ ពិស្តារប្រាំពីរចប់ និង ខួបគម្រប់១០ឆ្នាំ និងគម្រប់១៦ឆ្នាំ ជូន **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** អតីតប្រធានព្រឹទ្ធសភា និង**លោកជំទាវ ញ៉ែម សឿន ជាស៊ីម** នៅស្រុកកំចាយមារ ខេត្តព្រៃវែង។
- បានអញ្ជើញជាអធិបតីក្នុងពិធីចែកវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ តាមគោលការណ៍ ប្រទានកម្មរបស់រាជរដ្ឋាភិបាល ជូនវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប និងប្រជាពលរដ្ឋ ៥១គ្រួសារ ក្នុងសហគមន៍ព្រែកខ្ទិត នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមក្នុងពិធីបុណ្យខួបគម្រប់១០០ថ្ងៃ ឧទ្ទិសមហាកុសលជូនវិញ្ញាណក្ខន្ធ **ឯកឧត្តមអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** នៅខណ្ឌទួលគោក រាជធានីភ្នំពេញ និង
- បានអញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់៧ថ្ងៃ **លោក សួន វាសនាវិទ្ធិសក្តិ** ត្រូវជាចៅ របស់ **ឯកឧត្តម ង៉ែត ចង្ការី** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា និងជាសមាជិកក្រុម សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នៅខណ្ឌទួលគោក រាជធានីភ្នំពេញ។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធី "រុក្ខទិវា" ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅស្រុកចំការលើ ខេត្ត កំពង់ចាម។
- បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលជាមួយសិស្ស និស្សិត និងលោកគ្រូ អ្នកគ្រូ នៃមជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាល ជា ស៊ីម កំចាយមារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅស្រុកកំចាយមារ ខេត្តព្រៃវែង។
- បានអញ្ជើញចូលរួមក្នុងពិធីដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធចំពោះវីរយុទ្ធជន វីរយុទ្ធនារី និង ប្រជាជនកម្ពុជាក្នុងឱកាសរំលឹកខួបលើកទី៤៨ នៃទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំ របបប្រល័យពូជសាសន៍ ប៉ុល ពត ២០ មិថុនា ១៩៧៧-២០ មិថុនា ២០២៥ នៅតំបន់ ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម X១៦ នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

- បានអញ្ជើញចូលរួមពិធីបុណ្យពុទ្ធាភិសេក និងឆ្លងសារមន្ទីរ ពិស្តារប្រាំពីរចប់ និងខួបគម្រប់១០ឆ្នាំ និងគម្រប់១៦ឆ្នាំ ជូន **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** អតីតប្រធានព្រឹទ្ធសភា និង**លោកជំទាវ ញ៉ែម សឿន ជាស៊ីម** នៅស្រុកកំចាយមារ ខេត្តព្រៃវែង។
- បានអញ្ជើញចូលរួមស្តាប់បទបង្ហាញរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ក្រោមអធិបតីភាពរបស់ **លោកជំទាវ មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងជាប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- បានយាង និងអញ្ជើញគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជន ដែលបានពលីក្នុងបុព្វហេតុការពារបូរណភាពទឹកដី ដែនអធិបតេយ្យជាតិ និងបានចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ ព្រមទាំងនាំយកសម្ភារៈ និងស្បៀងអាហារបម្រុងជាបន្តបន្ទាប់ ដើម្បីឧបត្ថម្ភជូនកងទ័ពជួរមុខ និងជនភៀសសឹក នៅតាមបណ្តាភូមិភាគនានា។
- បានអញ្ជើញចូលរួមប្រជុំក្រុមសមាជិកាព្រឹទ្ធសភា ដើម្បីពិនិត្យលើខ្លឹមសាររបាយការណ៍ចុះជួបសំណេះសំណាល ឈ្វេងយល់ពីតម្រូវការ បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី នៅភូមិភាគទី៧ នៅសាលប្រជុំគណៈកម្មការទី៨ វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមពិធីទូងស្គរអបអរសាទរការដាក់បញ្ចូល "បូជនីយដ្ឋានចងចាំនៃកម្ពុជាៈ ពីទីតាំងឧក្រិដ្ឋកម្មមកជាមណ្ឌលផ្សះផ្សា និងសន្តិភាព" ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា នៅមុខសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារផ្នែកឯកជន វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ដើម្បីពិគ្រោះយោបល់បន្ទាន់រកគ្រប់វិធីជួយសម្រួលដល់ការលំបាករបស់កសិករ ពាណិជ្ជករ អាជីវករ ទេសចរណ៍ និងការដឹកជញ្ជូន នៅសភាពាណិជ្ជកម្មកម្ពុជា។
- បានអញ្ជើញជាគណៈអធិបតី និងផ្តល់បទបាឋកថាលើប្រធានបទ "ការផ្លាស់ប្តូរពីការធ្វើកសិកម្មបែបប្រពៃណី ទៅជាកសិកម្មកែច្នៃតាមបែបទំនើប" នៅក្នុងវេទិកាធុរកិច្ច និងនវានុវត្តន៍ នៅសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ។
- បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម សុក ខា** អតីតអនុប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ នៅខណ្ឌចំការមន រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ **ចំនួន៦លើក** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា រួមមានៈ

  ១/ ពិធីអបអរសាទរដំណើរការជាផ្លូវការ ១ឆ្នាំ របស់សមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា និងពិសាភោជនាហារសាមគ្គីឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ។

  ២/ ទិវាមច្ឆជាតិ ១ កក្កដា ២០២៥ នៅខេត្តតាកែវ។

  ៣/ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា ផ្ទះស្នាក់នៅគ្រូ ទីចាត់ការ និងសមិទ្ធផលនានា នៅខេត្តកំពង់ស្ពឺ។

  ៤/ ពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារថ្មី និងសម្ពោធឆ្លងសមិទ្ធផលនានា នៅវត្តពោធិព្រឹក្សាខារាម (វត្តតូប) នៅខេត្តកំពត។

៥/ ពិធីអបអរសាទរការដាក់បញ្ចូល "បូជនីយដ្ឋានចងចាំនៃកម្ពុជា៖ ពីទីតាំងឧក្រិដ្ឋកម្មមកជាមណ្ឌលផ្សះផ្សា និងសន្តិភាព" ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៅរាជធានីភ្នំពេញ និង
៦/ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ មជ្ឈមណ្ឌលផ្តាឈូក អង្គភាពការពារកុមារ នៃអង្គការមូលនិធិកុមារកម្ពុជា នៅខេត្តកណ្តាល។

- ❖ ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌលសុខភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា **ចំនួន១០៧លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន១៣៧លើក**។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ អញ្ជើញដង្ហែ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះរាជពិធី "រុក្ខទិវា" នៅស្រុកចំការលើ ខេត្តកំពង់ចាម។
- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញចុះពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ និងអញ្ជើញជួបសំណេះសំណាលជាមួយសិស្ស និស្សិត និងលោកគ្រូ អ្នកគ្រូ នៃមជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាល ជា ស៊ីម កំចាយមារ សរុបជាង១៣ាន់នាក់ នៅស្រុកកំចាយមារ ខេត្តព្រៃវែង។
- អញ្ជើញចូលរួមពិធីសាសនាផ្សេងៗ រួមទាំងពិធីបង្សុកូល និងរាប់បាត្រ ក្នុងពិធីបុណ្យគម្រប់ខួប១០ឆ្នាំ និងគម្រប់ខួប១៦ឆ្នាំ នៃការចូលមរណភាពរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** អតីតប្រធានព្រឹទ្ធសភា និង**លោកជំទាវ ញ៉ែម សឿន ជាស៊ីម** នៅស្រុកកំចាយមារ ខេត្តព្រៃវែង និង
- អញ្ជើញចូលរួមពិធីបុណ្យទក្ខិណានុប្បទានគម្រប់ខួប១០០ថ្ងៃ ដើម្បីឧទ្ទិសមហាកុសលជូនដួងវិញ្ញាណក្ខន្ធ **ឯកឧត្តមអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** នៅខណ្ឌទួលគោក រាជធានីភ្នំពេញ។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និងឯកឧត្តម **អោក ប៉ូវ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញនាំយកទៀនចំណាំព្រះវស្សា ទេយ្យទាន ទេយ្យវត្ថុ ព្រមទាំងបច្ច័យប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា នៅវត្តវារិន្ទព្រែកលាប និងវត្តមង្គលសត្ថារ៉ែន នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង
  - អញ្ជើញគោរពវិញ្ញាណក្ខន្ធសព **លោកជំទាវ ហូ ប៉ូវ៉ាលីន** ភរិយា **ឯកឧត្តមសាស្ត្រាចារ្យ គង់ សន្យា** អគ្គនាយកមន្ទីរពេទ្យកាល់ម៉ែត នៅគេហដ្ឋាននៃសព ស្ថិតនៅសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។
- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម អោក ប៉ូវ៉ា** និងឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីទូងស្គរអបអរសាទរការដាក់បញ្ចូល "បូជនីយដ្ឋានចងចាំនៃកម្ពុជា៖ ពីទីតាំងឧក្រិដ្ឋកម្មមកជាមណ្ឌលផ្សះផ្សា និងសន្តិភាព" ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។
- **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក ប៉ូវ៉ា** និងឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជូន និងទទួលដំណើរ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភាដឹកនាំគណៈប្រតិភូជាន់ខ្ពស់សភាកម្ពុជា ចូលរួមសម័យប្រជុំប្រចាំឆ្នាំលើកទី៥០ នៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងប៉ារីសនៃសាធារណរដ្ឋបារាំង នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- **ឯកឧត្តម ខេង សិទ្ធិគុណ** និងឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមឧត្តមសេនីយ៍ឯក ដួង សំនៀង** មេបញ្ជាការកងពលតូចអន្តរាគមន៍លេខ៧ កងពលធំអន្តរាគមន៍លេខ៣ កងទ័ពជើងគោក នៅវត្តនិរោធរង្សី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ និង
  - អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាអំពីការងារចុះទៅព្រំដែន និងការងារពាក់ព័ន្ធផ្សេងៗ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។
- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញសួរសុខទុក្ខ **លោក អឿ ស៊ីផុន** ចៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យកាល់ម៉ែត និង
  - អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងចូលរួមក្នុងពិធីផ្សេងៗ ចំនួន៥លើក។
- **ឯកឧត្តម អោក ប៉ូវ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញនាំយកទៀនចំណាំព្រះវស្សា ទេយ្យទាន ទេយ្យវត្ថុ ព្រមទាំងបច្ច័យប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា ចំនួន២វត្ត នៅស្រុកព្រែកប្បាស ខេត្តតាកែវ និង

- អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងចូលរួមក្នុងពិធីផ្សេងៗ ចំនួន៩លើក។

❖ **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងចូលរួមក្នុងពិធីផ្សេងៗ ចំនួន៦លើក។

❖ សមាជិក សមាជិកាសហភាពសហព័ន្ធយុវជនកម្ពុជា នៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបាន៖

- អញ្ជើញបរិច្ចាគឈាមមនុស្សធម៌ តាមការអំពាវនាវរបស់ **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** អនុប្រធានក្រុមប្រឹក្សាភិបាលសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) នៅមជ្ឈមណ្ឌលមហាសន្និបាតកោះពេជ្រ និង
- អញ្ជើញនាំយកស្បៀងអាហារ និងសម្ភារៈប្រើប្រាស់ជូនដល់ប្រជាពលរដ្ឋភៀសសឹក ចំនួន៣៧៩គ្រួសារ នៅខេត្តព្រះវិហារ។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងឱកាសនៃពិធីចម្រើនជន្មាយុ គោរពជូន៖
  - **ឯកឧត្តម ឯក សំអុល** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។
  - **ឯកឧត្តម សូ ស៊ីនួន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។
  - **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និង
  - **លោកជំទាវ និន សាផុន** ប្រធានគណៈកម្មការទី៩រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន៖
  - **លោកជំទាវ ទេស ថាន** និងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឯកឧត្តម ញ៉ូវ សាឯម** ទីប្រឹក្សាសម្តេចតេជោ និងជាអតីតប្រធានក្រុមប្រឹក្សាខេត្តកំពត។
  - **លោកជំទាវ ស្វាយ ណេង** និងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឯកឧត្តមនាយឧត្តមសេនីយ៍ សុខ ភាព** រដ្ឋលេខាធិការក្រសួងការពារជាតិ។
  - **លោកជំទាវ អ៊ុក ស៊ុនរ៉ានី** និងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឯកឧត្តមឧត្តមសេនីយ៍ឯក ដួង សំនៀង** មេបញ្ជាការកងពលតូចអន្តរាគមន៍លេខ៧ កងពលធំអន្តរាគមន៍លេខ៣ កងទ័ពជើងគោក។
  - **ឯកឧត្តមឧត្តមសេនីយ៍ឯក រ័ត្ន ស្រ៊ាង** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ និង**លោកជំទាវ** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឧបាសិកា កាំង ម៉េងហ៊ាង**។
  - **លោកជំទាវ ភាវ សុខា** និងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឯកឧត្តមឧត្តមសេនីយ៍ទោ ឈុំ ខេង** មេបញ្ជាការកងពលតូចអន្តរាគមន៍លេខ៦ ចំណុះកងពលធំអន្តរាគមន៍លេខ២ និង
  - **ឯកឧត្តម ង៉ែត ចង្ការី** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា និងជាសមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ និងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **លោក សួន វាសនាវិទ្ធិសក្តិ**។

- បានធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសាវតារបស់ព្រឹទ្ធសភា ជូនប្រតិភូសមាគមនិស្សិតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន នៅវិមានព្រឹទ្ធសភា ចំនួន១០៦នាក់ និង
- បានទទួលពាក្យបណ្តឹង ចំនួន៨បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន៤បណ្តឹង ធ្វើលិខិតរំលឹកជំរុញការដោះស្រាយ ចំនួន៥បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន៦បណ្តឹង ធ្វើកំណត់បង្ហាញគោរពរាយការណ៍ជូន **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា អំពីការឆ្លើយតបលទ្ធផលដោះស្រាយបណ្តឹងរបស់ក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន១បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន៩បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន៥បណ្តឹង បានទទួលលិខិតថ្លែងអំណរគុណពីម្ចាស់បណ្តឹងគោរពជូន **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា តាមរយៈគណៈកម្មការ ចំនួន១បណ្តឹង។

## ៤-មុខងារសហប្រតិបត្តិការអន្តរជាតិ

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖**

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិចូលជួបសម្តែងការគួរសម និងជម្រាបលា នៅវិមានព្រឹទ្ធសភា ចំនួន១៥លើក រួមមាន៖

- **ឯកឧត្តម** Abdullah Muhammad Ibrahim Al-Sheikh ប្រធានសភានៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត។
- **លោកជំទាវ** Maria Fernanda Lay ប្រធានរដ្ឋសភាជាតិនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។
- **ឯកឧត្តម** Lawrence Wong នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសិង្ហបុរី។
- **ឯកឧត្តម** Nagashima Akihisa សមាជិករដ្ឋសភា និងជាទីប្រឹក្សាពិសេសនាយករដ្ឋមន្ត្រីជប៉ុន។
- **ឯកឧត្តម** Wang Zhimin សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាអនុប្រធានគណៈកម្មាធិការកិច្ចការជនជាតិភាគតិចនៃសភាតំណាងប្រជាជនចិន។
- **ឯកឧត្តម** Pabitra Margherita អនុរដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋឥណ្ឌា។
- **ឯកឧត្តមឧត្តមសេនីយ៍ឯក** Roy Mabagos Galido មេបញ្ជាការកងទ័ពជើងគោកនៃសាធារណរដ្ឋហ្វីលីពីន។
- **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត** Dato Sri Tahir សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌូណេស៊ី និងជាស្ថាបនិកក្រុមហ៊ុន Mayapada Group។
- **លោកជំទាវ** Ar. Siti Rozaimeriyanty Dato Haji Abdul Rahman អគ្គលេខាធិការអន្តរសភាអាស៊ាន (AIPA)។
- **ឯកឧត្តម** Ermenegildo Kupa Lopes ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។
- **ឯកឧត្តម** Jacques pellet ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង។
- **ឯកឧត្តម** Martin Vávra ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឆែក។

- **ឯកឧត្តម Park Jong-wook** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េ។
- **លោក Yoshihisa Kainuma** ប្រធាន និងជានាយកប្រតិបត្តិក្រុមហ៊ុន Minebea Mitsumi Inc. នៃប្រទេសជប៉ុន និង
- **លោក Fahd AI Dosari** ប្រធានផ្នែកទំនាក់ទំនង និងជាទីប្រឹក្សាពិសេសនៃ Sheikh Mansour bin Jabor AI Thani នៃក្រុមហ៊ុន AI Mansour Asia នៃប្រទេសកាតា។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន២លើក រួមមាន៖
  - **លោកស្រី ប្រៃហ្គេត អែល វ៉ែកឃឺរ** ភារធារីស្តីទីនៃស្ថានទូតសហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា និង
  - **ឯកឧត្តម អូស្មាន សាហ្គុឡាម** សមាជិករដ្ឋសភាតួកគីយេ នៅបន្ទប់ទទួលភ្ញៀវឯកឧត្តម អនុប្រធានទី១ វិមានព្រឹទ្ធសភា។
- **សកម្មភាពការងារនៅក្រៅប្រទេស៖**
  - បានអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់សភានៃព្រះរាជាណាចក្រកម្ពុជា ចូលរួមសម័យប្រជុំប្រចាំឆ្នាំលើកទី៥០ នៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង។
  - បានអញ្ជើញចូលរួមពិធីបើកផ្លូវការនៃសម័យប្រជុំប្រចាំឆ្នាំសភាប្រើភាសាបារាំង លើកទី៥០ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម Gérard LARCHER** ប្រធានព្រឹទ្ធសភាបារាំង និង
  - បានអញ្ជើញថ្លែងបទអន្តរាគមន៍ទៅកាន់ប្រធាន សមាជិក និងសមាជិកានៃសភាប្រើភាសាបារាំង ប្រមាណ៥៥០នាក់ ដោយសង្កត់ធ្ងន់ទៅលើបញ្ហាប្រទេសថៃរំលោភដែនអធិបតេយ្យកម្ពុជា និងមិនគោរពចំពោះយុត្តាធិការតុលាការយុត្តិធម៌អន្តរជាតិ (ICJ)។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ចន្ទ្រា អនុប្រធានទី២ព្រឹទ្ធសភា** បានអនុញ្ញាតឱ្យគណៈប្រតិភូសមាគមកាហ្វេកម្ពុជា (Cambodia Coffee Association) ដឹកនាំដោយ **លោក ឌុក ពិសិដ្ឋ** ចូលជួបសម្តែងការគួរសម និងគោរពសុំការណែនាំ និងទស្សនវិស័យអំពីអនាគតនៃឧស្សាហកម្មកាហ្វេនៅកម្ពុជា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

❖ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយអ្នកវិនិយោគជប៉ុន-ចិន ដើម្បីស្វែងរកឱកាសបណ្តាក់ទុនលើវិស័យកសិកម្ម កសិឧស្សាហកម្ម នៅខេត្តកំពង់ស្ពឺ។

❖ **ឯកឧត្តម អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំប្រចាំឆ្នាំលើកទី៥០ នៃសភាប្រើភាសាបារាំង (APF) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងប៉ារីសនៃសាធារណរដ្ឋបារាំង។

- ❖ **ឯកឧត្តម ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញទទួលស្វាគមន៍ **លោក គីម ផុងណាម** ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ក្នុងឱកាសដែលអញ្ជើញមកបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- ❖ **ឯកឧត្តម គង់ មុនីកា** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា និង**ឯកឧត្តម សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបុណ្យឯករាជ្យជាតិខួបលើកទី២៤៩ នៃសហរដ្ឋអាមេរិក ដែលរៀបចំដោយស្ថានទូតសហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ភូគីត្រា។
- ❖ **ឯកឧត្តម គង់ មុនីកា** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយ ឯកឧត្តមឯកអគ្គរាជទូតប្រទេសអង់គ្លេស ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅស្ថានទូតអង់គ្លេស រាជធានីភ្នំពេញ និង
- ❖ សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបើក និងពិធីបិទកិច្ចប្រជុំក្រុមអ្នកនយោបាយអាយប៉ា (AIPA Caucus) លើកទី១៦ ស្តីពី "សន្តិភាពតាមរយៈការសន្ទនា៖ មាគ៌ាឆ្ពោះទៅមុខរបស់សភា" នៅអគាររដ្ឋបាល វិមានរដ្ឋសភា។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**
  - ❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបសម្តែងការគួរសមដោយភ្ញៀវអន្តរជាតិនៅវិមានព្រឹទ្ធសភា ចំនួន១៥លើក។

- បានចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរគុណរបស់ **ឯកឧត្តម តូ ឡឹម** អគ្គលេខាធិការគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម និង**ឯកឧត្តម លឿង គឿង** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលបានផ្ញើសារលិខិតរំលែកទុក្ខ និងបញ្ជូនគណៈប្រតិភូជាន់ខ្ពស់កម្ពុជាគោរពវិញ្ញាណក្ខន្ធ និងចូលរួមក្នុងពិធីរំលឹកវិញ្ញាណក្ខន្ធសព **ឯកឧត្តម** Tran Duc Luong អតីតប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
- បានចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរគុណរបស់ **ឯកឧត្តម** Igor Krasnov អគ្គរដ្ឋអាជ្ញានៃសហព័ន្ធរុស្ស៊ី គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលបានផ្តល់កិត្តិយសអនុញ្ញាតជូន **ឯកឧត្តម** ចូលជួបសម្តែងការគួរសម នៅព្រះរាជាណាចក្រកម្ពុជា។
- បានចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរគុណរបស់ **ឯកឧត្តម** Xavier Bettel ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស កិច្ចការអឺរ៉ុប ការពារជាតិ កិច្ចសហប្រតិបត្តិការ និងពាណិជ្ជកម្មក្រៅប្រទេសនៃបូរីក្សេម្ពួ គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ចំពោះបដិសណ្ឋារកិច្ចដ៏កក់ក្តៅជូន គណៈប្រតិភូលុចសំបួ ក្នុងអំឡុងពេល **ឯកឧត្តម** អមព្រះរាជដំណើរទស្សនកិច្ចជាន់ខ្ពស់របស់ព្រះអង្គម្ចាស់ Guillaume Jean Joseph Marie រជ្ជទាយាទនៃបូរីក្សេម្ពួ នៅព្រះរាជាណាចក្រកម្ពុជា ។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា គោរពជូន **ឯកឧត្តម Gérard Larcher** ប្រធានព្រឹទ្ធសភាបារាំង ក្នុងឱកាសនៃទិវាបុណ្យជាតិសាធារណរដ្ឋបារាំង។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា គោរពជូន **ឯកឧត្តម តូ ឡឹម** អគ្គលេខាធិការគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ក្នុងឱកាសដ៏វិសេសវិសាលនៃថ្ងៃកំណើតរបស់ឯកឧត្តម និង
- បានសហការ និងទាក់ទងជាមួយស្ថានទូតចិន មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ(CFRD) មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន(CALRC) មជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន បណ្ណាសារដ្ឋានជាតិ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ក្នុង-ក្រៅប្រទេស ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកកៀរគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៥.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
  - អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
  - អញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាអំពីការត្រៀមគំនូសរូបភាពប្រទីបព្រឹទ្ធសភា សម្រាប់ចូលរួមអបអរសាទរក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០២៥ នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ។
  - អញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាអំពីការអនុវត្តប្រាក់សោធននិវត្តន៍សម្រាប់បុគ្គលនៃវិស័យសាធារណៈ នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ និង
  - អញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមរៀបចំសេចក្តីសម្រេចអំពីការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ។
- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអមដំណើរ **ឯកឧត្តម ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញចុះត្រួតពិនិត្យមើលវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មីនៃព្រឹទ្ធសភា ដោយផ្ទាល់ នៅវិមានព្រឹទ្ធសភា។
- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា តំណាង **ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា** បានអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា អញ្ជើញចុះត្រួតពិនិត្យវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មីនៃព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។
- **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំពិនិត្យពិភាក្សា និងសម្រេចលើការស្នើគម្រោងថវិកាឆ្នាំ២០២៦ របស់ព្រឹទ្ធសភា មុនដាក់ស្នើ

កម្រិតបច្ចេកទេស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅបន្ទប់ប្រជុំឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា និង

- **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានដឹកនាំក្រុមការងាររៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋព្រឹទ្ធសភា ប្រជុំត្រួតពិនិត្យ និងធ្វើកំណត់ហេតុលើបញ្ជីសម្ភារៈ គ្រឿងសង្ហារិម ដែលនឹងត្រូវជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋព្រឹទ្ធសភា ឆ្នាំ២០២៥ នៅសាលពិសេសព្រឹទ្ធសភា។

**៩.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ**

- បានបោះពុម្ពផ្សាយអាណត្តិថ្លៃប្រើប្រាស់អគ្គិសនី ចាប់ពីខែកុម្ភៈ ដល់ខែឧសភា ឆ្នាំ២០២៥ បញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានទូទាត់បុរេប្រទានថវិកា សម្រាប់ចំណាយលើបេសកកម្មក្រៅប្រទេសរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ច នៅសាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋឥណ្ឌូណេស៊ី ប្រទេសអ៊ូសបេគីស្ថាន និងសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ចំនួន៣បុរេប្រទាន។
- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែកក្កដា ឆ្នាំ២០២៥ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភាចូលនិវត្តន៍ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និវត្តជន មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ប្រមុខរដ្ឋស្ដីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការ ប្រចាំខែកក្កដា ឆ្នាំ២០២៥ តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់វិភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកក្កដា ឆ្នាំ២០២៥។
- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៣៩សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន១៨០សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារៈអនាម័យ សម្ភារៈការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន៣៦សំណើ។
- បានថតចម្លងឯកសារ ចំនួន៣,៥១០ច្បាប់ ប្រើប្រាស់ក្រដាសអស់ ចំនួន៣១,២៦៩សន្លឹក។
- បានផ្ដល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្ដាភូមិភាគទាំង៨ ចំនួន ៧០លើក ស្មើនឹង២១៨នាក់។

- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន៤៤លើក។
- បានទទួលលិខិតចូល ចំនួន៧៤២ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ចំនួន៤៤២ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៥១ច្បាប់ ស្មើនឹង២០៣នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៦ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការមានជំងឺ គ្រោះថ្នាក់ចរាចរណ៍ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និងខេត្តកំពង់ឆ្នាំង ចំនួន១២នាក់។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមានៈ
  - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១៣លើក។
  - បានកែលម្អសួនខាងក្នុង និងខាងលើអគារក្រហម ចំនួន៤២៥គុម្ព។
  - បានដាំដើមជ្រៃភ្នំ និងដើមឫស្សី ចំនួន៦១គុម្ព។
  - បានបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅតាមសួនច្បារនានា និង
  - បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានសម្របសម្រួលការរៀបចំគូរប្លង់រចនាទេសភាពសួនច្បារស្រះត្រី និងសួនច្បារសាលពិសេស
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកក្កដា មានចំនួន៧១៥នាក់ (ស្រី២៨៩នាក់) ក្នុងនោះ
  - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរដោយគ្មានបៀវត្ស ចំនួន១២នាក់។
  - មន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំនួន៥នាក់។
  - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩២នាក់ និង
  - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៨៧នាក់ (ស្រី៣៥នាក់)។
- បានធ្វើសេចក្តីសម្រេច ចំនួន៥ច្បាប់ និងលិខិតបង្គាប់ការ ចំនួន៣ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្តត់ផ្គង់ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៤ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែកក្កដា ឆ្នាំ២០២៥។
- បានសហការជាមួយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ រៀបចំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនសមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងក្រុមគ្រួសារ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំធ្វើបច្ចុប្បន្នភាពប័ណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ជូនមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

- បានសម្របសម្រួល និងរៀបចំការផ្តល់អាហារូបករណ៍ ចំនួន៣២កន្លែង របស់សាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សាកលវិទ្យាល័យអាស៊ីអឺរ៉ុប សាកលវិទ្យាល័យវ៉ាន់ដា និងបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ជូនដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានដាក់ចេញផែនការវគ្គបណ្តុះបណ្តាលសម្រាប់ឆមាសទី២ ឆ្នាំ២០២៥ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានបញ្ជូនមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅស្ថាប័នព្រឹទ្ធសភា ចំនួន៤វគ្គ មានសិក្ខាកាមចំនួន២២នាក់ រួមមាន៖
  - វគ្គ "ភាសាជប៉ុនសម្រាប់វិស័យការទូតកម្រិតដំបូង" នៅវិទ្យាស្ថានជាតិការទូត។
  - វគ្គ "ភាពជាអ្នកដឹកនាំដែលមានការផ្លាស់ប្តូរ" នៅវិមានរដ្ឋសភា។
  - វគ្គ "ការស្រាវជ្រាវ និងការវិភាគច្បាប់ គោលនយោបាយសម្រាប់ជាជំនួយដល់ការធ្វើសេចក្តីសម្រេចចិត្ត" នៅមជ្ឈមណ្ឌលសភាអាស៊ី និង
  - វគ្គ "វិធីសាស្ត្រសរសេរសេចក្តីប្រកាសព័ត៌មានតាមនិយាម និងចាប់មុម ដើម្បីសរសេរដំណឹងឱ្យមានការទាក់ទាញ" នៅមជ្ឈមណ្ឌលសភាអាស៊ី។
- ការងារសាងសង់សំណង់ថ្មីៗ ជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងបរិវេណវិមានព្រឹទ្ធសភា រួមមាន៖
  - បានជួសជុលកែលម្អ និងធ្វើស្លាកឈ្មោះបន្ទប់ នៅអគារក្រហម។
  - បានប្តូរពិដានសំយ៉ាប ដំបូល នៅអគារដាក់ម៉ាស៊ីន Server និងនាយកដ្ឋានព័ត៌មានវិទ្យា ព្រមទាំងបានប្តូរដំបូលជ័រប៉ូលីកាប៉ោន នៅមុខបន្ទប់ទឹកសាលពិសេស៣។
  - បានប្តូរអ្វូតទ្វារកញ្ចក់ នៅនាយកដ្ឋានរដ្ឋបាល។
  - បានជួសជុលផ្ទាំងប៉ាណូ នៅច្រកចេញ-ចូល P2។
  - បានសហការជាមួយក្រុមការងារស្ថាបត្យករ **លោក វណ្ណ មូលីវណ្ណ** ធ្វើការវាស់វែងអគារដែលជាស្ថាបត្យកម្មចាស់ មានដូចជា អគារក្រុមប្រឹក្សាធម្មនុញ្ញ អគារក្រុមប្រឹក្សានៃអង្គចៅក្រម និងអគារសហភាពសហព័ន្ធយុវជនកម្ពុជា និង
  - បានស្តារប្រព័ន្ធលូ ចាប់ពីសាលពិសេស រហូតដល់ខាងមុខក្រុមប្រឹក្សាធម្មនុញ្ញ។
- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី ត្រួតពិនិត្យជណ្តើរយន្ត កំចាត់សត្វកណ្តៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារៈខូច បិទលេខកូដសម្ភារៈសារពើភ័ណ្ឌ និងបំពាក់សម្ភារៈការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន៩៥គ្រឿង/លើក។
- បានស្រាវជ្រាវ និងរៀបចំចងក្រងសៀវភៅអំពីការវិវឌ្ឍនៃការប្រើប្រាស់អគារមួយចំនួន នៅវិមានព្រឹទ្ធសភា។
- បានសម្របសម្រួលការងារការដ្ឋាន និងបានរៀបចំរបាយការណ៍វឌ្ឍនភាពការងារសាងសង់អគារថ្មីនៃព្រឹទ្ធសភា រៀងរាល់ ២សប្តាហ៍ម្តង គោរពជូនថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានធ្វើស្លាកលេខរថយន្តព្រឹទ្ធសភាថ្មី ជូនសមាជិកព្រឹទ្ធសភា ចំនួន២ឈុត។

- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែកក្កដា ឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកក្កដា ឆ្នាំ២០២៥ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធនានា និង
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកក្កដា ឆ្នាំ២០២៥។

### ៥.៣-ការងារសេវាច្បាប់៖

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេច និងលិខិតផ្សេងៗ ចំនួន ៣៨ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានទទួលសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចំនួន១ច្បាប់ ពីរដ្ឋសភា ព្រមទាំងបានថ្វាយ និងចែកគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា។
- បានរៀបចំឯកសារជំនួយស្មារតីក្នុងកិច្ចដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន៣លើក។
- បានរៀបចំឯកសារជំនួយស្មារតីជូនលេខាធិការសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
- បានរៀបចំឯកសារជំនួយស្មារតីជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រាយការណ៍ជូនអង្គប្រជុំ ចំនួន៣លើក។
- បានធ្វើសេចក្តីជូនដំណឹងស្តីពី ការជ្រើសតាំងសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ។
- បានធ្វើកំណត់ហេតុពិស្តារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា សម័យប្រជុំព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន១០លើក។
- បានធ្វើបច្ចុប្បន្នភាពកម្មវិធីចុះបេសកកម្មរបស់គណៈកម្មការទាំង១០ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ ចំនួន២លើក។
- បានធ្វើបច្ចុប្បន្នភាព ប្រមូលផ្តុំចងក្រងឯកសារនានា រួមមាន៖
  - សម្រង់សង្ខេបសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ តាមនីតិកាលនីមួយៗ។
  - សម្រង់លទ្ធផលសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥។
  - បញ្ជីឈ្មោះច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ តាមឆ្នាំនីមួយៗ និងតាមនីតិកាល និង
  - តារាងទិន្នន័យ ស្ថិតិ សមាសភាព លេខទូរស័ព្ទរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អាណត្តិទី៥។
- បានទទួលសៀវភៅកម្រងឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រឆាំងអំពើពុករលួយ ពីអង្គភាពប្រឆាំងអំពើពុករលួយ ចំនួន២០០ច្បាប់។

- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ធ្វើរបាយការណ៍ និងរៀបចំកំណត់បង្ហាញ ឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន៣០៥លើក។
- បានសម្រួលបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល លាលែងពីមុខតំណែង ចំនួន១នាក់ និងបានប្រគល់ឯកសារចុះបញ្ជី ប្រថាប់ត្រាអង្គភាពប្រឆាំងអំពើពុករលួយជូនសាមីខ្លួនរក្សាទុក ចំនួន៥ច្បាប់ និង
- បានរៀបចំរបាយការណ៍ប្រកាសទ្រព្យសម្បត្តិ និងបំណុល ប្រចាំឆមាសទី១ ឆ្នាំ២០២៥ គោរពជូនឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា និងអង្គភាពប្រឆាំងអំពើពុករលួយ ចំនួន២ច្បាប់។

**៩.៨-ការងារស្រាវជ្រាវ៖**

- បានរៀបចំឯកសារស្រាវជ្រាវ និងឯកសារជំនួយស្មារតីលើសេចក្តីស្នើច្បាប់ស្ដីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- បានសិក្សាស្រាវជ្រាវ និងតាមដានវឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធតាមវិស័យនានា។
- បានសិក្សាស្រាវជ្រាវលើ៖
    - ផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២៦-២០២៨។
    - ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា និង
    - របាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។
- បានសិក្សា និងតាមដាន៖
    - ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។
    - យុទ្ធសាស្រ្តស្តីពី ការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០២៤-២០២៨ និង
    - របាយការណ៍ និន្នាការសេដ្ឋកិច្ច-សង្គម ប្រចាំខែរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានតាមដានការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍នៃខែកក្កដា ឆ្នាំ២០២៥ ចំនួន៤ច្បាប់។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន២៣១ព័ត៌មាន និង
- បានបញ្ចូលព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ២៧-៣២ ឆ្នាំ២០២៤)។

**៩.៩-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន១១លើក។

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្តាញសង្គម ចំនួន១,២២៦លើក។
- បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន២០៤សកម្មភាព។
- បានអញ្ជើញអ្នកសារព័ត៌មាន ចូលយកព័ត៌មានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន១៦លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភានៅខ្លោងទ្វារខាងមុខព្រឹទ្ធសភា ចំនួន១៨លើក។
- បានរៀបចំផលិតទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែកក្កដា ឆ្នាំ២០២៥។
- បានសិក្សាស្រាវជ្រាវ ចងក្រងព្រឹត្តិបត្រ និងផ្សព្វផ្សាយព័ត៌មានស្តីពី បច្ចេកវិទ្យាព័ត៌មាន ចំនួន២០ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និងជួសជុលឧបករណ៍ សម្ភារៈ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន៥៥គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធសូឌីយ៉ូ ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំ ជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៦៤លើក។
- បានទទួលឯកសារ សៀវភៅច្បាប់ ទស្សនាវដ្តី រាជកិច្ច និងសៀវភៅជំនាញផ្សេងៗ ចំនួន១៩៦ក្បាល ព្រមទាំងបានចុះបញ្ជីសៀវភៅ បោះត្រាបិទប័ណ្ណខ្ចី និងសងសៀវភៅ ចំនួន៧០ក្បាល។
- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារជំនាញផ្សេងៗ និងសៀវភៅជា E-Book តាមគេហទំព័រ www.elibrary.senate.gov.kh ចំនួន៧,៦៧២ក្បាល ដែលមានសាធារណជនចូលអាន ចំនួន១,០២៨នាក់ (ដោយគិតត្រឹមខែកក្កដា ឆ្នាំ២០២៥) និង
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ថែងតម្កល់រក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបានរៀបចំសៀវភៅព្រឹត្តិបត្រព្រឹទ្ធសភា(ស្ទួន) ឆ្នាំ២០១៤ ចំនួន៥៦១ក្បាល ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន៣៤សំណុំ។

**៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

- បានរៀបចំចាត់ថែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៥១លើក។
- បានរៀបចំសារលិខិតជូនពរ លិខិតអបអរសាទរ និងលិខិតរំលែកទុក្ខ របស់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូនឥស្សរជនជាន់ខ្ពស់ និងថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានា ចំនួន៥លិខិត។

- បានរៀបចំកំណត់បង្ហាញ លិខិតឆ្លើយតប និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៣ច្បាប់/លើក។
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែកក្កដា ឆ្នាំ២០២៥ ចំនួន១ច្បាប់។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៦ច្បាប់ និង
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការ ជូនសមាជិក ទីប្រឹក្សាព្រឹទ្ធសភា ព្រមទាំងក្រុមគ្រួសារ ចំនួន៣រូប។

**៩.៧-ការងារអគ្គាធិការដ្ឋាន៖**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកក្កដា ឆ្នាំ២០២៥ ចំនួន២២លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវា ប្រចាំខែកក្កដា ឆ្នាំ២០២៥។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែកក្កដា ឆ្នាំ២០២៥ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមាន ប្រចាំថ្ងៃ ចំនួន៤៦លើក ប្រចាំសប្តាហ៍ ចំនួន៤លើក និងប្រចាំខែកក្កដា ឆ្នាំ២០២៥ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារៈតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែសីហា ឆ្នាំ២០២៥

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ និង
- ត្រៀមប្រជុំផែនការថវិការបស់ព្រឹទ្ធសភា ឆ្នាំ២០២៦ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបសវនាការជាមួយក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

## ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍ នៅថ្នាក់ក្រោមជាតិ ចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា។
- ត្រៀមផ្ដល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន រួមមាន៖
  - ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញចុះឈ្វេងយល់អំពីបញ្ហាប្រឈម និងសំណូមពរពីមូលដ្ឋាន នៅខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញ និង
  - ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ទី៣ ទី៤ ទី៥ ទី៦ ទី៧ និងទី៨ អញ្ជើញជួបសំណេះសំណាលជាមួយអង្គបោះឆ្នោត និងអ្នកពាក់ព័ន្ធ ព្រមទាំងចូលរួមដោះស្រាយ និងនាំយកយោបល់សំណូមពរ ឬបញ្ហានានា ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នៅខេត្តកែប ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តកណ្ដាល ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តរតនគិរី និងខេត្តបន្ទាយមានជ័យ។
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន សិស្ស និស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្ដល់សេវាចាំបាច់បម្រើការងារការទូតសភា ការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។
- ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា៖
  - អញ្ជើញចូលរួមសន្និសីទប្រធានសភាពិភពលោក លើកទី៦ និងកិច្ចប្រជុំកំពូលលើកទី១៥ នៃប្រធានសភាជាស្ត្រី នៅប្រទេសស្វីស និង
  - អញ្ជើញចូលរួមសន្និសីទសភាអាស៊ី-ប៉ាស៊ីហ្វិកស្ដីពី បរិស្ថាន និងការអភិវឌ្ឍលើកទី២១ (21st APPCED) នៅទីក្រុងសេអ៊ូលនៃសាធារណរដ្ឋកូរ៉េ។
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិក្នុងជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថានអនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តផ្ដល់សេវាផ្គត់ផ្គង់សម្ភារៈ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង
- បន្តចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

**III-សេចក្ដីសន្និដ្ឋាន**

ខែកក្កដា ជាខែទី១នៃវិស្សមកាលរយៈពេលបីខែរបស់ព្រឹទ្ធសភា ចាប់ពីថ្ងៃទី៧ ខែកក្កដា ដល់ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៥។ ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា គណៈកម្មការទាំង១០ព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា និងក្រុមយន្តការនានា បានបង្កើនសកម្មភាពការងារក្នុងការបំពេញមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង តាមរយៈការចុះមូលដ្ឋាន នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត និងជំនួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ទិសដៅ និងបញ្ហាប្រឈមការផ្សព្វផ្សាយច្បាប់ ការអនុវត្តច្បាប់ និងគោលនយោបាយនានា របស់រាជរដ្ឋាភិបាល ជាពិសេសដើម្បីពង្រឹងតួនាទី ភារកិច្ច របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណនេយ្យភាពជាមួយអង្គបោះឆ្នោត។

ក្នុងបរិបទនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំ និងយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្ដល់សេវាបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនសម្រេចបានលទ្ធផលគួរជាទីមោទនៈ។

ក្រៅពីផ្ដល់សេវានៅមូលដ្ឋាន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏បានផ្ដល់សេវាលើមុខងារនីតិកម្ម ដោយបានរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ និងបានរៀបចំជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជាមួយភ្ញៀវជាតិ និងអន្តរជាតិ បានដោយរលូន ទទួលបានលទ្ធផលផ្លែផ្កា ជាគុណប្រយោជន៍ជូនជាតិមាតុភូមិ។

ក្នុងបរិការណ៍ដែលប្រទេសជាតិទទួលរងនូវការវាយប្រហារឈ្លានពានពីសត្រូវ ក្រៅពីបំពេញមុខងារស្នូលរបស់ខ្លួន ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានធ្វើសកម្មភាពរួមគ្នាយ៉ាងសស្រាក់សស្រាំរួមជាធ្លុងសាមគ្គីភាពជាតិ គាំទ្របុព្វហេតុការពារបូរណភាពទឹកដី និងបាននាំយកអំណោយស្បៀងអាហារ សម្ភារៈប្រើប្រាស់ ជូនកងទ័ពនៅសមរភូមិមុខ និងប្រជាពលរដ្ឋភៀសសឹក នៅតាមបណ្ដាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ។

ថ្ងៃអង្គារ ៧ រោច ខែ អស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥

**អគ្គលេខាធិការ**

**ឡាយ សំកុល**